# ៣ចំណុច ធ្វើឲ្យ គូនីឡា ជាប់ឈ្មោះក្នុងបញ្ជីយុវជនឆ្នើម របស់ Forbes

សុក្រ, 21 មេសា 2017 11:28
ចំនួនមតិ 0

ចន្លោះមិនឃើញ

ទស្សនាវដ្ដីដ៏ល្បីល្បាញរបស់សហរដ្ឋអាមេរិក Forbes កន្លងទៅថ្មីៗនេះ បានចេញផ្សាយនូវ បញ្ជីឈ្មោះសហគ្រិនឆ្នើមនៅអាស៊ី ប្រចាំឆ្នាំ២០១៧ចំនួន៣០០នាក់ ដែលមានវ័យក្រោម ៣០ឆ្នាំ។ ក្នុងនោះ កញ្ញា កែវ គូនីឡា ជាយុវតីម្នាក់គត់ក្នុងចំណោមយុវជនកម្ពុជា ៣រូប បានជាប់ឈ្មោះនៅក្នុងបញ្ជីទស្សនាវដ្ដី Forbes នៅក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយ ទីផ្សារ និងពាណិជ្ជកម្ម។ តើមានមូលហេតុអ្វីខ្លះទៅ ធ្វើឲ្យ កញ្ញា មានឈ្មោះក្នុងបញ្ជីយុវសហគ្រិនឆ្នើម របស់ទស្សនាវដ្ដីល្បីខាងលើនោះ?




ជួបជាមួយ Sabay កញ្ញា គូនីឡាដែលបច្ចុប្បន្នជាទីប្រឹក្សាផ្នែកសារព័ត៌មាន និងជាស្ថាបនិក នៃភ្នាក់ងារផ្ដល់សេវាកម្មបែបឌីជីថល Mekhala និងជាសហស្ថាបនិក នៃគេហទំព័រ wheninphnompenh.com (http://wheninphnompenh.com/) បានប្រាប់ថា មានកត្តាសំខាន់ ៣ ដែលធ្វើឲ្យ នាងបានជាប់ឈ្មោះក្នុងទស្សនាវដ្ដី Forbes ៖

**១. បទពិសោធន៍ការងារ**

នៅអាយុ១៨ឆ្នាំ (ពេលកំពុងរៀននៅដេប៉ាតឺម៉ង់ ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍) គូនីឡាបានចាប់ផ្តើមអាជីព ក្នុងវិស័យសារព័ត៌មាន។ បើគិតមកទល់ពេលនេះ គឺរយៈពេល ១១ឆ្នាំដែលកញ្ញាប្រឡូកក្នុងវិស័យនេះ។

ចាប់តាំងពីឆ្នាំ២០០៨ គូនីឡា បានបម្រើការងារ ជាអ្នកសារព័ត៌មាន (freelance writer )ឲ្យទីភ្នាក់ងារព័ត៌មានបរទេសជាច្រើន ដូចជា Agence France Presse (AFP) របស់បារាំង Los Angeles Times IRIN UN News Agency the Independent UK CSMonitor the Phnom Penh Post Asia360s (ទស្សនាវដ្តី) Global Voices Online ជាដើម។



ក្រៅពីការងារ ជាអ្នកសរសេរព័ត៌មាន គូនីឡា បានធ្វើការងារជាច្រើនទៀតក្នុងវិស័យទីផ្សារ និងពាណិជ្ជកម្ម តាមរយៈការទទួលធ្វើគម្រោងមួយចំនួន។

**២. សកម្មភាពលេចធ្លោ ទាំងក្នុង និងក្រៅប្រទេស**

និស្សិតបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត គោលនយោបាយសាធារណៈ នៅសាកលវិទ្យាល័យជាតិសិង្ហបុរីខាងលើ បានចូលរួមសកម្មភាពសង្គមជាច្រើន ទាំងក្នុងស្រុក និងនៅបរទេស។



គូនីឡា ធ្លាប់បណ្តុះបណ្តាលទៅដល់សិស្ស និស្សិតខ្មែរ និងនិស្សិតបរទេស អំពីការប្រើប្រាស់បណ្តាញសង្គម និងផ្នែកទីផ្សារឌីជីថល។

នៅខែតុលា ឆ្នាំ២០១១ កញ្ញាត្រូវបានជ្រើសរើសជាអ្នកសរសេរប្លុកម្នាក់ ដែលបានចម្រាញ់ចេញពីបេក្ខជនជិត៦០០នាក់ ដើម្បីទៅសរសេរពីវេទិកាយុវជន របស់អង្គការយូណេស្កូ នៅប៉ារីស។

ឆ្នាំ២០១២ កញ្ញាបានក្លាយជា អ្នកបណ្តុះបណ្តាលផ្នែកបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គមទៅដល់ សន្និសិទយុវជន Seliger Youth Forum នៅប្រទេសរុស្ស៊ី។

គូនីឡាក៏ធ្លាប់ជា អ្នកប្រឹក្សាប្រព័ន្ធផ្សព្វផ្សាយសង្គមដល់ក្រសួងកិច្ចការយុវជនរបស់រុស្ស៊ី និងក្រុមប្រឹក្សាទេសចរណ៍ របស់ប្រទេសឥណ្ឌូណេស៊ី និងឥណ្ឌាផងដែរ។



### ៣. អ្នកប្រើប្រាស់បណ្ដាញផ្សព្វផ្សាយ ដែលមានឥទ្ធិពល

កញ្ញា គូនីឡា មានប្លុក (Blog) ផ្ទាល់ខ្លួនមួយឈ្មោះ Blueladyblog.com (http://blueladyblog.com/) ដែលសរសេររៀបរាប់ពី ប្រវត្តិសិក្សា និងបទពិសោធន៍ការងាររបស់នាង។ បន្ថែមពីនោះ កញ្ញាជាសហស្ថាបនិកនៃ គេហទំព័រ WhenInPhnomPenh.com (http://wheninphnompenh.com/) ដែលជាវិបសាយអនឡាញ ណែនាំពីព័ត៌មានសំខាន់ៗផ្សេងៗក្នុងការដើរកម្សាន្តនៅរាជធានីភ្នំពេញ និងជាគេហទំព័រផ្ដល់ឱកាសឲ្យយុវជនជាច្រើនចែករំលែក ចំណេះដឹង និងការយល់ឃើញ អំពីរាជធានីភ្នំពេញផងដែរ។

ដោយសារស្នាដៃខាងលើ បានធ្វើឲ្យក្រុមការងារទស្សនាវដ្ដី Forbes ទទួលស្គាល់ពីកិច្ចការរបស់នាង និងចាត់ទុក គូនីឡា ជាអ្នកមានបទពិសោធន៍ ក្នុងផ្នែកប្រព័ន្ធផ្សព្វផ្សាយ ទីផ្សារ និងពាណិជ្ជកម្ម របស់អាស៊ី ប្រចាំឆ្នាំ២០១៧។

គួររំលឹកដែរថា ទស្សនាវដ្ដី Forbes បានចេញផ្សាយបញ្ជី បុគ្គលឆ្នើម ទាំង៣០ ដែលមានអាយុក្រោម៣0ឆ្នាំ ( 30 Under 30 Asia) ប្រចាំឆ្នាំ២០១៧ ក្នុងនោះមានយុវជនជាច្រើន ដែលមានសក្ដានុពលផ្នែកសហគ្រិនភាព និងការបង្កើតថ្មី។ បញ្ជី Forbes ចែកចេញជា ១0ផ្នែក រួមមាន សិល្បៈ កម្សាន្ត និងកីឡា ហិរញ្ញវត្ថុ និងការបណ្ដាក់ទុន ឧស្សាហកម្ម កម្មន្តសាល និងថាមពល ប្រព័ន្ធផ្សព្វផ្សាយ ទីផ្សារ និងពាណិជ្ជកម្ម លក់ដូរ និងពាណិជ្ជកម្មអេឡិចត្រូនិក ការថែសុខភាព និងវិទ្យាសាស្ត្រ សហគ្រិនសង្គម បច្ចេកវិទ្យាសហគ្រាស និងសេវាកម្មបច្ចេកវិទ្យា៕

×





អត្ថបទ៖ មាន រតនា

(HTTPS://TWITTER.COM/INTENT/TWEET?TEXT=%E1%9F%A3%E2%80%8B%E1%9E%85%E1%9F%86%E1%9E%8E%E1%9E%BB%E1%9E%85+%E1%9E%92%E1%9F%92%E1%9E%9C%E1%9E%BE%E2%80%8B%E1%9E%B2%E1%9F%92%E1%9E%99%E2%80%8B%E2%80%8B+%E1%9E%82%E1%9E%BC%E1%9E%93%E1%9E%B8%E1%9E%A1%E1%9E%B

(MAILTO:?SUBJECT=៣ ចំណុច ធ្វើឲ្យ គូនីឡាដាប់ ឈ្មោះក្នុង បញ្ជី យុវជន ឆ្នើម របស់ FORBES&BODY=HTTP://NEWS.SABAY.COM.KH/ARTICLE/925702)

## ពាក្យទាក់ទង

ព័ត៌មានសង្គម (http://news.sabay.com.kh/article/tag/ព័ត៌មានសង្គម)

### ភ្ជាប់ទំនាក់ទំនងជាមួយ Sabay News Social

Like Share You and 129K others like this.

## អត្ថបទទាក់ទង